ASIAN
DECENT WORK 2006
DECADE 2015

International
Labour
Organization

# ការពារសុខភាព និងអាជីវកម្ម របស់អ្នក ពីជំងឺផ្តាសាយបក្សី

## សៀវភៅណែនាំអំពីសកម្មភាព សម្រាប់ កសិករ និងអ្នកធ្វើការងារជាមួយបសុបក្សី

Tsuyoshi Kawakami
Laddawalaya Ratananakorn



គម្រោងផ្តាសាយបក្សី និង ផ្តាសាយមនុស្សនៅកន្លែងធ្វើការ (ប្រទេសថៃ)
ការិយាល័យអនុតំបន់អាស៊ីបូព៌ា

# ការពារសុខភាព និងអាជីវកម្ម
# របស់អ្នក ពីជំងឺផ្តាសាយបក្សី

## សៀវភៅណែនាំអំពីសកម្មភាពសម្រាប់
## កសិករ និងអ្នកធ្វើការងារជាមួយបសុបក្សី

Tsuyoshi Kawakami
Laddawalaya Ratananakorn

ការរក្សាសិទ្ធិ © អង្គការពលកម្មអន្តរជាតិ ២០០៩
បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ ២០០៩

ការបោះពុម្ពផ្សាយរបស់ការិយាល័យពលកម្មអន្តរជាតិ ទទួលការរក្សាសិទ្ធិ ក្រោមពិធីសារទី ២ នៃអនុសញ្ញាស្តីពីការរក្សាសិទ្ធិជាសកល។ ថ្វីបើដូច្នេះក្តី សម្រង់ខ្លីៗចេញពីឯកសារទាំងនេះ អាចផលិតឡើងវិញបាន ដោយមិនចាំបាច់មានការអនុញ្ញាត ឱ្យតែមានបញ្ជាក់ពីប្រភពដើមនៃសម្រង់នេះ។ ចំពោះសិទ្ធិផលិតឡើងវិញ ឬបកប្រែឯកសារនេះ គប្បីដាក់ពាក្យសុំទៅផ្នែកបោះពុម្ពផ្សាយ (ផ្នែកសិទ្ធិ និងការអនុញ្ញាត) នៃការិយាល័យពលកម្មអន្តរជាតិ អាស័យដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស ឬតាមអ៊ីមែល pubdroit@ilo.org ។ ការិយាល័យពលកម្មអន្តរជាតិ សូមស្វាគមន៍ចំពោះការដាក់ពាក្យសុំ ។

បណ្ណាល័យ ស្ថាប័ននានា និងអ្នកប្រើប្រាស់ឯទៀតៗ ដែលមានចុះបញ្ជីនៅចក្រភពអង់គ្លេស ជាមួយទីភ្នាក់ងារផ្តល់អាជ្ញាប័ណ្ណរក្សាសិទ្ធិ អាស័យដ្ឋាន 90 Tottenham Court Road, London W1T 4LP [ ទូរសារ : (+44) (0)20 7631 5500 អ៊ីមែល : cla@cla.co.uk] ឬនៅសហរដ្ឋ អាមេរិក ជាមួយមជ្ឈមណ្ឌលជម្រះការរក្សាសិទ្ធិ (Copyright Clearance Center) ដែលមានអាស័យដ្ឋាន 222 Rosewood Drive, Danvers, MA 01923 [ ទូរសារ : (+1) (978) 750 4470 អ៊ីមែល : info@copyright.com] ឬនៅក្នុងប្រទេសដទៃទៀត ជាមួយនឹងអង្គការផ្តល់សិទ្ធិ ផលិតឡើងវិញ អាចថតចម្លងការបោះពុម្ពផ្សាយទាំងនេះបាន ដោយអនុលោមទៅតាមអាជ្ញាប័ណ្ណ ដែលបានចេញឱ្យពួកគេសម្រាប់គោលបំណងនេះ ។

---

Kawakami, Tsuyoshi; Ratananakorn, Laddawalaya
ការពារសុខភាព និងអាជីវកម្មរបស់អ្នកពីជំងឺផ្តាសាយបក្សី : សៀវភៅណែនាំអំពីសកម្មភាពសម្រាប់កសិករ និងអ្នកធ្វើការងារជាមួយបសុបក្សី/ Tsuyoshi Kawakami និង Laddawalaya Ratananakorn គម្រោងផ្តាសាយបក្សី និងផ្តាសាយមនុស្សនៅកន្លែងធ្វើការ (ប្រទេសថៃ) ការិយាល័យអនុតំបន់របស់ ILO ប្រចាំអាស៊ីបូព៌ា នាយកដ្ឋានអភិវឌ្ឍន៍បសុសត្វ ក្រសួងកសិកម្ម និងសហករណ៍-បាងកក : ILO, 2009 ។ 32 p.

ISBN: 978-92-2-822345-3; 978-92-2-822346-0 ( pdf )

ការិយាល័យអនុតំបន់របស់ ILO ប្រចាំអាស៊ីបូព៌ា គម្រោងផ្តាសាយបក្សី និងផ្តាសាយមនុស្សនៅកន្លែងធ្វើការ (ប្រទេសថៃ) ក្រសួងកសិកម្ម និងសហករណ៍ នាយកដ្ឋានអភិវឌ្ឍន៍បសុសត្វ សៀវភៅណែនាំសម្រាប់អ្នកបណ្តុះបណ្តាល/ សុខភាពការងារ/ សុវត្ថិភាពការងារ/ ជំងឺវិទ្ធាជីវ:/ ជំងឺឆ្លង/ កសិករ/ ភ្នាក់ងារកសិកម្ម/ បក្សី/ បញ្ជីផ្ទៀងផ្ទាត់
13.04.2

*កាតាឡុករបស់អង្គការពលកម្មអន្តរជាតិ នៅក្នុងទិន្នន័យបោះពុម្ពផ្សាយ*

---

ការរចនាប្លង់បោះពុម្ពដែលមានប្រើនៅក្នុងការបោះពុម្ពផ្សាយរបស់ ILO ស្របទៅតាមការអនុវត្តរបស់អង្គការសហប្រជាជាតិ និងទស្សនៈយោបល់ ដែលមានបង្ហាញនៅក្នុងឯកសារបោះពុម្ពនេះ មិនបញ្ជាក់ថាជាការបញ្ចេញមតិយោបល់អ្វីមួយ ដោយការិយាល័យពលកម្មអន្តរជាតិនោះទេ ទាក់ទងទៅនឹងស្ថានភាពផ្នែកច្បាប់ នៃប្រទេសណាមួយ តំបន់ ឬទីកន្លែងណាមួយ ឬអាជ្ញាធរនៃប្រទេស តំបន់ ឬទីកន្លែងទាំងនោះ ឬទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងទាំងនោះ ។

ការទទួលខុសត្រូវចំពោះមតិយោបល់ដែលបានលើកឡើងនៅក្នុងអត្ថបទ ដែលមានចុះហត្ថលេខាក្តី ក្នុងការសិក្សា និងការរួមវិភាគទានផ្សេងៗទៀតក្តី ត្រូវធ្លាក់ទៅលើអ្នកនិពន្ធទាំងស្រុង ហើយការបោះពុម្ពផ្សាយនេះមិនមានន័យថា ជាការឯកភាពតាមដោយការិយាល័យពលកម្មអន្តរជាតិ ចំពោះមតិយោបល់ដែលបានលើកឡើងនៅក្នុងអត្ថបទនោះទេ ។

សេចក្តីយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ព្រមទាំងដំណើរការផលិត មិនបញ្ជាក់ថា ការិយាល័យពលកម្មអន្តរជាតិ មានការឯកភាពតាមសេចក្តីយោងទាំងនោះឡើយ ហើយការដែលមិនបានបញ្ចេញឈ្មោះក្រុមហ៊ុនណាមួយ ផលិតផលពាណិជ្ជកម្មណាមួយ ឬដំណើរការផលិត ក៏មិនមែនជាសញ្ញានៃការមិនយល់ស្របដែរ ។

ការបោះពុម្ពផ្សាយរបស់ ILO អាចរកបាននៅតាមបណ្ណាគារធំៗ ឬនៅតាមការិយាល័យរបស់អង្គការ ILO នៅក្នុងប្រទេសជាច្រើន ឬអាចរកបានដោយផ្ទាល់ពីផ្នែកបោះពុម្ពផ្សាយរបស់ ILO នៅឯការិយាល័យពលកម្មអន្តរជាតិ អាស័យដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស ឬការិយាល័យប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក អាស័យដ្ឋានជាន់ទី 11 អាគារសហប្រជាជាតិ វិថី Rajdamnern Nok បាងកក 10200 ប្រទេសថៃ ឬតាមអ៊ីមែល pubvente@ilo.org ។

សូមចូលមើលវិបសាយរបស់យើង : www.ilo.org/publns ឬ www.ilo.org/asia

---

បោះពុម្ពនៅក្នុងប្រទេសកម្ពុជា

# មាតិកា

ទំព័រ


អារម្ភកថា......................................................................................................................៥

បញ្ជីផ្ទៀងផ្ទាត់សកម្មភាព.........................................................................................................៧

ចំណុចផ្ទៀងផ្ទាត់ទី ១ : ប្រមូលព័ត៌មានអំពីជំងឺផ្តាសាយបក្សី ដើម្បីការពារសុខភាពរបស់អ្នក............................១៥

ចំណុចផ្ទៀងផ្ទាត់ទី ២ : កាន់បសុបក្សីរបស់អ្នកដោយសុវត្ថិភាព..................................................................១៧

ចំណុចផ្ទៀងផ្ទាត់ទី ៣ : ប្រើប្រាស់វិធីសាស្ត្រសម្លាប់បសុបក្សី ដែលមានសុវត្ថិភាព...........................................២០

ចំណុចផ្ទៀងផ្ទាត់ទី ៤ : អនុវត្តវិធីសាស្ត្រចោលកាកសំណល់ និងគ្រប់គ្រងកាកសំណល់ ប្រកបដោយអនាម័យ.......២៣

ចំណុចផ្ទៀងផ្ទាត់ទី ៥ : រាយការណ៍ពីជំងឺឱ្យបានឆាប់រហ័ស.........................................................................២៦

ឧបសម្ព័ន្ធទី ១ : ប្រភពព័ត៌មាន..................................................................................................២៩

# អារម្ភកថា

ការផ្ទុះឡើងនូវជំងឺផ្តាសាយបក្សី និងការកើតឡើងជាបន្តបន្ទាប់នូវជំងឺឆ្លងនានា បានបង្កឱ្យមានការព្រួយបារម្ភនៅទូទាំងសកលលោក ។ ដោយដឹងពីសារៈសំខាន់នៃការបង្ការការរាលដាលជំងឺផ្តាសាយបក្សី អង្គការពលកម្មអន្តរជាតិ (ILO) បានផ្តួចផ្តើមឱ្យមានគម្រោងសាកល្បងមួយ ដែលមានឈ្មោះថា "គម្រោងផ្តាសាយបក្សី និងផ្តាសាយមនុស្សនៅកន្លែងធ្វើការ (ប្រទេសថៃ)" ។ គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាពីមូលនិធិកណ្តាលរបស់សហប្រជាជាតិសម្រាប់សកម្មភាពប្រយុទ្ធនឹងជំងឺផ្តាសាយ (CFIA) ។

សកម្មភាពមួយ ក្នុងចំណោមសកម្មភាពសំខាន់ៗ របស់គម្រោងនេះ គឺបង្កើតសំភារៈបណ្តុះបណ្តាល ដើម្បីផ្សព្វផ្សាយពីការអនុវត្តប្រកបដោយសុវត្ថិភាព នៅកន្លែងធ្វើការ ។ សៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះ គឺជាផលិតផលមួយ ដែលកើតឡើងចេញពីការចុះមូលដ្ឋានជាច្រើនលើក (ជាទីដែលត្រូវសង្កេតអំពីការអនុវត្តនូវវិធានការបង្ការជំងឺផ្តាសាយបក្សីល្អៗ នៅក្នុងឧស្សាហកម្មបសុបក្សី) នៅក្នុងប្រទេសថៃ និងចេញពីការពិគ្រោះយោបល់ជាមួយក្រសួងសុខភាពសាធារណៈ ក្រសួងការងារ និងក្រសួងកសិកម្ម និងសហករណ៍ របស់ប្រទេសថៃ ព្រមទាំងអង្គការស្បៀង និងកសិកម្ម (FAO) អង្គការសុខភាពពិភពលោក (WHO) និងអង្គការងារ UNSIC (ប្រព័ន្ធសម្របសម្រួលជំងឺផ្តាសាយរបស់សហប្រជាជាតិ) ព្រមទាំងទីភ្នាក់ងារសហប្រជាជាតិដទៃទៀត ។ ការសង្កេតឃើញជាក់ស្តែងទាំងនេះ គឺជាគោលសម្រាប់ផលិតរូបភាព និងខ្លឹមសាររបស់សៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះ ។

សៀវភៅណែនាំនេះ គឺងាយស្រួលសម្រាប់ប្រើប្រាស់ និងមានលក្ខណៈជាការអនុវត្តជាក់ស្តែង ដោយមានបញ្ជីផ្ទៀងផ្ទាត់សកម្មភាពស្តីពីវិធានការបង្ការ អមដោយការពន្យល់ និងការពិពណ៌នា ។ វិធីបណ្តុះបណ្តាលតាមបែបជាការចូលរួម ដែលមានលក្ខណៈពិសេសប្លែកគេ របស់អង្គការពលកម្មអន្តរជាតិ គឺកម្មវិធីការកែលំអការងារ និងអភិវឌ្ឍន៍ភូមិដ្ឋាន (WIND) និងកម្មវិធីកែលំអការងារនៅតាមសហគ្រាសខ្នាតតូច (WISE) ត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងចំណោមប្រជាជនគោលដៅ ។

ដែនអនុវត្តន៍នៃសៀវភៅណែនាំអំពីការបណ្តុះបណ្តាល និងបញ្ជីផ្ទៀងផ្ទាត់សកម្មភាពរបស់គម្រោងនេះ នឹងមិនកម្រិតត្រឹមប្រទេសថៃនោះទេ ។ ផ្ទុយទៅវិញ សៀវភៅណែនាំ និងបញ្ជីផ្ទៀងផ្ទាត់នេះ អាចយកទៅកែសម្រួលអោយស្របទៅនឹងបរិបទ និងតម្រូវការ របស់ប្រទេសផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីជំងឺផ្តាសាយបក្សី ។

ក្រុមអនុវត្តគម្រោងរបស់អង្គការពលកម្មអន្តរជាតិ រួមជាមួយនឹង Dr. Laddawalaya Ratananakom នៃនាយកដ្ឋានអភិវឌ្ឍន៍បសុសត្វ ក្រសួងកសិកម្ម និងសហករណ៍ ក្នុងប្រទេសថៃ បានរៀបចំអត្ថបទ និងបញ្ជី

ផ្សៀងផ្ទាត់នេះ ហើយបានត្រួតពិនិត្យលើការគូសរូបភាព ដែលប្រើប្រាស់នៅក្នុងសៀវភៅណែនាំនេះ។ ក្រុមរបស់អង្គការពលកម្មអន្តរជាតិ រួមមាន លោកបណ្ឌិត Tsuyoshi Kawakami អ្នកឯកទេសជាន់ខ្ពស់ផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់ការិយាល័យ ILO ប្រចាំអនុតំបន់អាស៊ីបូព៌ា លោកស្រី Duanne Punpiputt និងលោកស្រី Suttida Chaikitsakol អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ និងកញ្ញា Monrudee Sucharitakul លេខារបស់គម្រោង។ យើងខ្ញុំសូមថ្លែងនូវកតញ្ញូតាធម៌ចំពោះលោក Donato Kiniger-Passigli អ្នកឯកទេសជាន់ខ្ពស់ ផ្នែកដោះស្រាយវិបត្តិរបស់អង្គការពលកម្មអន្តរជាតិ (ILO CRISIS) និងកញ្ញា Jittima Srisuknam មន្ត្រីកម្មវិធី នៃការិយាល័យ ILO ប្រចាំអនុតំបន់អាស៊ីបូព៌ា ចំពោះការផ្តល់យោបល់ដ៏មានតម្លៃរបស់ពួកគាត់។

អង្គការពលកម្មអន្តរជាតិ សូមថ្លែងអំណរគុណជាពិសេស ចំពោះអ្នកទាំងអស់ដែលបានរួមចំណែក ក្នុងការបង្កើតសៀវភៅណែនាំ និងបញ្ជីផ្សៀងផ្ទាត់នេះ ហើយសង្ឃឹមថា សៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះ នឹងជួយធ្វើកែលម្អឱ្យកាន់តែប្រសើរនូវលក្ខខណ្ឌការងារ របស់កសិករ និងអ្នកធ្វើការងារជាមួយបសុបក្សី ដើម្បីបង្ការបាននូវជំងឺផ្តាសាយបក្សី។

**Bill Salter**

នាយក

ការិយាល័យ ILO ប្រចាំអនុតំបន់អាស៊ីបូព៌ា

ក្រុងបាងកក ប្រទេសថៃ

ខែ មករា ឆ្នាំ ២០០៩

## ជំងឺផ្តាសាយបក្សី

# បញ្ជីផ្ទៀងផ្ទាត់សកម្មភាព ដើម្បីកែលម្អនូវការត្រៀបលក្ខណៈរបស់អ្នកសម្រាប់ជំងឺផ្តាសាយបក្សី

### របៀបប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់

១. អានចំណុចនីមួយៗ ដោយប្រុងប្រយ័ត្ន។ រិះរកវិធីដើម្បីអនុវត្តវិធានការ។ ប្រសិនបើចាំបាច់ សួរអ្នកគ្រប់គ្រង និងកម្មករនិយោជិត នៅក្នុងក្រុមហ៊ុនរបស់អ្នក។

២. ប្រសិនបើវិធានការត្រូវបានអនុវត្តរួចហើយ ឬវិធានការនេះមិនចាំបាច់ ចូរគូសត្រង់ចម្លើយ **ទេ** នៅក្រោមសំនួរ "តើអ្នកស្នើឱ្យមានវិធានការកែលម្អឬទេ? បើអ្នកគិតថា វិធានការនេះមានតម្លៃ គូសត្រង់ចម្លើយ **បាទ/ចាស**។ ប្រើទីចំហនៅក្រោម **កំណត់សំគាល់** ដើម្បីសរសេររៀបរាប់ពីសំណូមពររបស់អ្នក ឬទីតាំងដែលត្រូវកែលម្អ។

៣. បន្ទាប់ពីអ្នកបានអានគ្រប់ចំណុចអស់ហើយ ចូរមើលចំណុចដែលអ្នកគូស **បាទ/ចាស**ម្តងទៀត។ ចូរជ្រើសរើសចំណុចមួយចំនួនតូច ដែលមានអត្ថប្រយោជន៍សំខាន់ជាងគេបំផុត រួចគូសត្រង់ពាក្យ **អាទិភាព** សម្រាប់ចំណុចទាំងនេះ។

៤. មុនបញ្ចប់ ត្រូវធានាឱ្យប្រាកដថា អ្នកបានគូស **ទេ** ឬ **បាទ/ចាស** តាមចំណុចនីមួយៗ ហើយចំពោះចំណុចខ្លះដែលអ្នកបានគូស **បាទ/ចាស** អ្នកបានគូស **អាទិភាព**។



## ១. ប្រមូលព័ត៌មាន



១. ប្រមូលព័ត៌មានអំពីជំងឺផ្តាសាយបក្សី ពីការិយាល័យកសិកម្ម បសុពេទ្យ ឬសុខាភិបាល និងពីព័ត៌មានតាមទូរទស្សន៍ និងវិទ្យុ ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................



២. ចែករំលែកព័ត៌មានថ្មីៗ ជាមួយគ្រួសារ និងអ្នកជិតខាងរបស់អ្នក ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................



៣. បង្រៀនកូនរបស់អ្នក កុំឱ្យប៉ះពាល់ និងញុំាបក្សីឈឺ ឬងាប់ និងកាកសំណល់របស់វា ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

## ២. ការកាន់បក្សី ដោយសុវត្ថិភាព




៤. លាងដៃទាំងពីររបស់អ្នកឱ្យបានស្អាតជាមួយសាប៊ូបន្ទាប់ពីកាន់បក្សីហើយ ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

៥. ប្រើវិធីជីវសុវត្ថិភាពជាមូលដ្ឋាន ដូចជា ធ្វើរបង ឬដាក់របាំង ដើម្បីកាត់បន្ថយហានិភ័យឆ្លងជំងឺផ្ដាសាយបក្សី ដល់បសុបក្សីរបស់អ្នក ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

៦. សំអាត និងសម្លាប់មេរោគក្នុងរោង ឬទ្រុងបក្សី និងឧបករណ៍នានា ឱ្យបានស្អាត នៅពេលដែលទ្រុងនៅទំនេរ និងមុនពេលដាក់ហ្វូងថ្មីចូល ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

៧. ប្រើម៉ាសការពារ និងស្រោមដៃឱ្យបានសមស្រប នៅពេលកាន់បក្សីដែលសង្ស័យ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

៨. រក្សាសំភារៈការពារ ប្រកបដោយអនាម័យ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

៩. ទិញមាន់ និងទា តែពីអ្នកលក់ដែលអ្នកស្គាល់ និងមានការអនុញ្ញាតត្រឹមត្រូវ ហើយកុំទិញពីប្រភពដែលអ្នកមិនស្គាល់ ។

តើអ្នកស្នើឱ្យមានសកម្មភាពនេះដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................




១០. បន្ទាប់ពីមើលកសិដ្ឋានដែលមានបសុបក្សីឈឺ អ្នកត្រូវងូតទឹកកក់សក់ ដុសខ្លួនជាមួយសាប៊ូ និងប្តូរសំលៀកបំពាក់ថ្មីស្អាត រាល់ពេល មុននឹងអ្នកចូលទៅក្នុងកសិដ្ឋានរបស់អ្នក ដើម្បីបង្ការកុំឱ្យជំងឺឆ្លងរាលដាល ។

តើអ្នកស្នើឱ្យមានសកម្មភាពនេះដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព



កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

## ៣. ការសម្លាប់បសុបក្សី  ដោយសុវត្ថិភាព



១១. រកកន្លែងមួយទុកសម្រាប់សម្លាប់បក្សី និងកាប់សាច់បក្សី និង កុំប្រើប្រាស់កន្លែងនេះ សម្រាប់គោលបំណងផ្សេងទៀត ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................



១២. ហ៊ុមព័ទ្ធកន្លែងសត្វឃាត ដើម្បីកុំឱ្យសត្វ បក្សីព្រៃ ឬសត្វល្អិតចូល ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................

..........................................................................

..........................................................................

១៣. អ្នកធ្វើការដែលចាប់កាន់បក្សី ត្រូវអនុវត្តអនាម័យល្អផ្ទាល់ខ្លួន ដូចជា លាងដៃឱ្យបានញឹកញាប់ ផ្លាស់ប្តូរសំលៀកបំពាក់មុន និងក្រោយពេល ចាប់កាន់បសុបក្សី និងពាក់អាវរៀមការពារ ម៉ាស និងស្បែកជើងកវែង ។ គួរបោកសំអាតសំភារៈទាំងនេះ ជារៀងរាល់ថ្ងៃ ។




តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

១៤. មុនពេលសម្លាប់បសុបក្សី ត្រូវសង្កេតមើលវា និងរករោគសញ្ញាជំងឺផ្តាសាយបក្សី ។ ក្នុងពេលសម្លាប់ បើអ្នកសង្ស័យថាមានរោគសញ្ញានៃជំងឺ អ្នកត្រូវចោលបក្សីងាប់នោះភ្លាម ដោយវិធីអនាម័យ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

១៥. ក្នុងពេលសម្លាប់បក្សី ត្រូវការពារបក្សីដែលងាប់មិនឱ្យប្រឡាក់នឹងកាកសំណល់របស់បក្សី ជាពិសេស អាចម៍ចេញពីពោះវៀន ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព



កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

១៦. បន្ទាប់ពីសម្លាប់ហើយ សង្កេតមើលសាច់បក្សី ដើម្បីធានាឱ្យប្រាកដថា គ្មានសញ្ញាបង្ហាញពីការប្រឡាក់នឹងអាចម៍បក្សី ។ បើមានសញ្ញាទាំងនេះ ត្រូវលាងសំអាតវាឱ្យស្អាត ជាមួយទឹកក្លរីន ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

១៧. មានខ្យល់ចេញចូល និងភ្លើងបំភ្លឺបានល្អ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................................

..............................................................................................

១៨. ប្រើថ្នាំការពារទឹកជ្រាប តាមជញ្ជាំង និងនៅលើកម្រាលឥដ្ឋ ដើម្បីងាយស្រួលសំអាត និងសម្លាប់មេរោគ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................................

..............................................................................................

១៩. រៀបចំធុងពិសេស ដើម្បីប្រមូល និងទុកចំណែកបក្សីដែលមិនអាចបរិភោគបាន ហើយយកវាទៅចោល ដោយវិធីអនាម័យ ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................................

..............................................................................................

២០. សំអាត និងសម្លាប់មេរោគនៅកន្លែងសម្លាប់បក្សី និងឧបករណ៍ឱ្យបានទៀងទាត់ ។ ធានាឱ្យប្រាកដថា ឧបករណ៍ទាំងនេះត្រូវបានទុកដាក់ក្នុងកន្លែងបិទជិត មិនមានសត្វកណ្តុរ និងសត្វល្អិតចូល ។



តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................................

..............................................................................................

## ៩. ការគ្រប់គ្រងកាកសំណល់ពីបសុបក្សី



២១. ដុត ឬកប់កាកសំណល់បសុបក្សីឱ្យបានជម្រៅយ៉ាងហោចណាស់ ៥០ សង់ទីម៉ែត្រ និងដាក់ថ្នាំសម្លាប់មេរោគពីលើកាកសំណល់ទាំងនោះមុនពេលកប់ និងដាក់ម្តងទៀតលើរណ្តៅក្រោយពេលកប់រួច ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................



២២. ជ្រើសរើសកន្លែងកប់ ដែលនៅឆ្ងាយពីទន្លេ ប្រឡាយ និងកន្លែងដទៃទៀតដែលមានទឹក ។ គួរធ្វើរបងព័ទ្ធជុំវិញកន្លែងកប់នេះ ដើម្បីកុំឱ្យឆ្កែ ឆ្មា ។ល។ ចូល ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................



២៣. ធានាឱ្យប្រាកដថា អ្នកធ្វើការងារទាំងអស់ដែលពាក់ព័ន្ធនឹងការចោលបសុបក្សី និងការគ្រប់គ្រងកាកសំណល់ អនុវត្តអនាម័យល្អផ្ទាល់ខ្លួន ដូចជា លាងដៃ និងផ្លាស់ប្តូរសំលៀកបំពាក់មុន និងក្រោយធ្វើការងារ ហើយលាងសំអាតអាវអៀម ម៉ាស និងស្បែកជើងកវែង ។ គួរបោកសំអាតសំភារៈទាំងនេះ ប្រកបដោយអនាម័យ ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..........................................................................................

..........................................................................................

..........................................................................................

## ៥. រាយការណ៍ពីជំងឺឱ្យបានឆាប់រហ័ស

២៤. ដឹងពីសញ្ញា និងរោគសញ្ញាបសុបក្សី ដែលឆ្លងជំងឺផ្ដាសាយបក្សី ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................

..............................................................................



២៥. សង្កេតមើលបសុបក្សីរបស់អ្នកដោយប្រុងប្រយ័ត្ន ជារៀងរាល់ថ្ងៃ ដើម្បីរកមើលសញ្ញាដំបូងៗនៃជំងឺផ្ដាសាយបក្សី ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................

..............................................................................



២៦. រាយការណ៍ពីបក្សីឈឺ និងងាប់ រួមទាំងបក្សីសង្ស័យភ្លាមៗ ទៅកាន់មេភូមិ ឬអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................

..............................................................................



២៧. នៅពេលដែលអ្នក ឬសមាជិកគ្រួសាររបស់អ្នកគ្រុនក្ដៅខ្លាំង និង ក្អកខ្លាំង កណ្ដាស ឬចុះខ្សោយ ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យ ឬជាមួយមណ្ឌលសុខភាពភ្លាម ។

តើអ្នកស្នើឱ្យមានវិធានការកែលម្អដែរឬទេ?

○ ទេ

○ បាទ/ចាស ○ អាទិភាព

កំណត់សំគាល់: ..............................................................................

..............................................................................

..............................................................................



# ចំណុចផ្សព្វផ្សាយទី ១

## *ប្រមូលព័ត៌មានអំពីជំងឺផ្តាសាយបក្សី ដើម្បីការពារសុខភាពរបស់អ្នក*

### អត្ថប្រយោជន៍សម្រាប់កសិករ/អ្នកធ្វើការជាមួយបសុបក្សី

កសិករ និងអ្នកធ្វើការជាមួយបសុបក្សី អាចការពារសុខភាពរបស់ខ្លួនបានកាន់តែប្រសើរ នៅពេលដែលពួកគេមានព័ត៌មានទាន់ហេតុការណ៍អំពីជំងឺផ្តាសាយបក្សី។ ជំងឺផ្តាសាយបក្សី គឺជាជំងឺរបស់បក្សី ហើយកម្រឆ្លងមកមនុស្សណាស់។ ប៉ុន្តែ វីរុសនេះអាចឆ្លងមកកសិករបាន ប្រសិនបើពួកគេប៉ះពាល់បក្សីមានជំងឺ ឬសំភារៈដែលមានប្រឡាក់ជាប់អាចម៍សត្វ ឈាម សត្វងាប់ គ្រឿងក្នុងបក្សី ឬវត្ថុរាវចេញពីខ្លួនបក្សី ដែលឆ្លងជំងឺនោះ។ វីរុសនេះអាចធ្វើឱ្យអន្តរាយដល់សុខភាពរបស់អ្នក ក៏ដូចជាប្រភពចំណូលរបស់អ្នក ដែលបានមកពីការលក់ និងចិញ្ចឹមបក្សី។ គ្រួសារ អ្នកជិតខាង និងអតិថិជន របស់អ្នកក៏អាចរងផលប៉ះពាល់ផងដែរ។

ចំណេះដឹង និងវិធានការការពារជំងឺផ្តាសាយបក្សី មានការវិវត្តន៍ជាបន្តបន្ទាប់។ កសិករជាច្រើនកំពុងប្រើប្រាស់វិធានការងាយៗ ចំណាយប្រាក់តិច ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺនេះ។ ប្រការសំខាន់ គឺអ្នកត្រូវដឹងនូវព័ត៌មានដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីការបង្ការជំងឺផ្តាសាយបក្សី។ ប្រការនេះអាចផ្តល់ឱ្យអ្នកនូវគំនិត ដែលអ្នកអាចយកមកអនុវត្តជាក់ស្តែងបាន អំពីរបៀបកែលំអកសិដ្ឋានបសុបក្សីរបស់អ្នក និងការពារខ្លួនអ្នក និងក្រុមគ្រួសារពីការឆ្លងជំងឺផ្តាសាយបក្សី។

### របៀបកែលំអ

១. ធានាឱ្យប្រាកដថា គ្រប់ប្រជាពលរដ្ឋក្នុងភូមិរបស់អ្នកដឹងនូវព័ត៌មានជាមូលដ្ឋានអំពីជំងឺផ្តាសាយបក្សី (រូបភាព១.២)។

២. ទាក់ទងមន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬមន្ត្រីសុខាភិបាល ដើម្បីប្រមូលព័ត៌មានទាន់ហេតុការណ៍ និងអំពីវិធានការបង្ការ។ សំខាន់ដូចគ្នានេះដែរ គឺអ្នកត្រូវដឹងពីស្ថានភាពជំងឺផ្តាសាយបក្សី ក្នុងស្រុកខេត្តរបស់អ្នក និងស្រុកខេត្តនៅជុំវិញ។

៣. យកចិត្តទុកដាក់ចំពោះព័ត៌មានតាមទូរទស្សន៍ កាសែត និងវិទ្យុអំពីជំងឺផ្តាសាយបក្សី និងអំពីដំបូន្មានសម្រាប់កសិករ។

៤. ពិភាក្សាព័ត៌មានដែលប្រមូលបានជាមួយគ្រួសាររបស់អ្នក។ បង្រៀនកូនរបស់អ្នក ឱ្យចៀសវាងប៉ះពាល់បក្សីឈឺ ឬ ងាប់ និង កាកសំណល់របស់វា។

### របៀបបង្កើនការសហការ

១. ចែករំលែកព័ត៌មានជាមួយអ្នកជិតខាង។អ្នកក៏អាចទទួលបានព័ត៌មានថ្មីៗពីពួកគេវិញផងដែរ។ ចែករំលែកព័ត៌មានអំពីជំងឺផ្តាសាយបក្សី ក្នុងកិច្ចប្រជុំរបស់ភូមិ ដើម្បីរក្សាចំណាប់អារម្មណ៍របស់កសិករ។

២. រៀនសូត្រ និងចែករំលែកការអនុវត្តល្អៗ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺផ្តាសាយបក្សី ដូចជា ពាក់ឧបករណ៍ការពារខ្លួន និងគ្រប់គ្រងកាកសំណល់។ ការអនុវត្តល្អៗអាចធ្វើទៅបាន ដោយចំណាយប្រាក់តិច មានប្រយោជន៍ជាពិសេស ដូចជា លាងដៃឱ្យបានស្អាត គ្របច្រមុះ និងមាត់ពេលក្អក ឬកណ្តាស់ ប្រើប្រាស់ក្រដាសអនាម័យ ដើម្បីទុកកំហាក ឬសំបោរ ហើយចោលក្រដាសទាំងនេះ ក្នុងធុងសម្រាម ដែលនៅជិតបំផុត ក្រោយប្រើប្រាស់រួច។

### គន្លឹះណែនាំបន្ថែម

១. ស្វែងរកព័ត៌មានត្រឹមត្រូវ និងទាន់ហេតុការណ៍។ កុំជឿព័ត៌មាននិយាយតគ្នា និងពាក្យចចាមអារ៉ាម។ ប្រសិនបើអ្នកមានចម្ងល់ និងសំនួរ ទាក់ទងមន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬមន្ត្រីសុខាភិបាល ដើម្បីសុំការបញ្ជាក់។

២. ត្រៀមលក្ខណៈចំពោះអ្វីដែលត្រូវធ្វើ នៅពេលជំងឺផ្តាសាយបក្សីឆ្លងរាលដាលមកដល់ភូមិរបស់អ្នកឬភូមិដែលនៅជុំវិញ។ ប្រមូលព័ត៌មានអំពីវិធានការគាំទ្រ និងសំណងពីរដ្ឋាភិបាល នៅពេលកសិករបាត់បង់បក្សី ដោយសារជំងឺផ្តាសាយបក្សី។

**ចំនុចដែលត្រូវចងចាំ**

ព័ត៌មានត្រឹមត្រូវ និងទាន់ហេតុការណ៍ នឹងការពារអ្នក គ្រួសាររបស់អ្នក និងចំណូលរបស់អ្នក។



រូបភាព ១.១ កសិករចាំបាច់ត្រូវប្រមូលព័ត៌មានដែលត្រឹមត្រូវ និងទាន់ហេតុការណ៍អំពីជំងឺផ្តាសាយបក្សី ដើម្បីការពារសុខភាព និងប្រាក់ចំណូល ។ យកចិត្តទុកដាក់ចំពោះព័ត៌មានតាមទូរទស្សន៍ និងវិទ្យុ ។ ចែករំលែកព័ត៌មានដែលប្រមូលបានជាមួយអ្នក ជិតខាង ។




រូបភាព ១.២ ពិគ្រោះយោបល់ជាមួយមន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬមន្ត្រីសុខាភិបាល នៅក្នុងភូមិ ឬស្រុករបស់អ្នក ប្រសិនបើអ្នកមានសំនួរ ឬចម្ងល់ ។

## ចំនុចត្រួតពិនិត្យទី ២

### *ប៉ះពាល់បក្សីរបស់អ្នកដោយសុវត្ថិភាព*

### អត្ថប្រយោជន៍សម្រាប់កសិករ/អ្នកធ្វើការងារជាមួយបក្សី

មានវិធីងាយៗ និង អស់ចំណាយតិចជាច្រើន ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺផ្តាសាយបក្សី មកកសិករ/អ្នកធ្វើការងារជាមួយបក្សី។ កសិករ/អ្នកធ្វើការងារជាមួយបក្សីជាច្រើននាក់ កំពុងប្រើប្រាស់វិធីសាស្ត្រជីវសុវត្ថិភាពងាយៗ ដូចជា ការធ្វើរបាំង ឬ ដាក់រនាំង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឆ្លងជំងឺផ្តាសាយបក្សីមកកាន់បក្សី។ ប្រភពចំណូល និង បក្សី នឹងអាចការពារប្រសើរជាងមុន តាមរយៈវិធានការជីវសុវត្ថិភាពងាយៗទាំងនេះ។ ការខិតខំប្រឹងប្រែងរិះរកវិធីប៉ះពាល់បក្សីដោយសុវត្ថិភាព ក៏នឹងជួយដល់កសិករដែលនៅជិតខាងអ្នកផងដែរ។

កសិករ/អ្នកធ្វើការងារជាមួយបក្សី កាន់តែប្រើវិធានការអនាម័យផ្ទាល់ខ្លួនល្អប្រសើរជាងមុន ដូចជា លាងដៃឱ្យបានស្អាត ឬ ប្រើប្រាស់ឧបករណ៍ការពារ នៅពេលប៉ះពាល់បក្សីឈឺ ឬ ងាប់។ អ្នកអាចការពារខ្លួនឯង និង ក្រុមគ្រួសារបានប្រសើរជាងមុន បន្ទាប់ពីអ្នកបានបង្កើតវិធីដែលមានសុវត្ថិភាព ដើម្បីប៉ះពាល់បក្សីរបស់អ្នក (ដូចជា វិធានការអនាម័យផ្ទាល់ខ្លួនល្អប្រសើរជាងមុន និង ការប្រើប្រាស់ឧបករណ៍ការពារ)។

### របៀបកែលំអ

១. ប្រើប្រាស់ម៉ាស និង ស្រោមដៃការពារ នៅពេលប៉ះពាល់ជាមួយបក្សី។ លាងដៃរបស់អ្នក (បាតដៃ ម្រាមដៃ កដៃ និង ខ្នងដៃទាំងសងខាង) ជាមួយសាប៊ូដោយប្រុងប្រយ័ត្ន ក្រោយពេលប៉ះពាល់បក្សីហើយ (រូបភាព ២.១)។

២. រៀបចំផែនការ និង ប្រើប្រាស់វិធានការជីវសុវត្ថិភាពងាយៗ ដូចជា ដាក់បក្សីនៅកន្លែង ដែលមានរបង ឬ សំណាញ់ព័ទ្ធជុំវិញ (រូបភាព ២.២) និង ដាក់កន្លែងសម្រាប់លាងជើងសម្លាប់ មេរោគនៅតាមគ្រប់ច្រកចូលទាំងអស់ ដើម្បីកាត់បន្ថយ ហានិភ័យដែលបក្សីរបស់អ្នកអាចឆ្លងជំងឺផ្តាសាយបក្សី ពីបក្សី ដទៃទៀត ។

៣. ដឹងពីរោគសញ្ញាបក្សីឆ្លងជំងឺផ្តាសាយបក្សីឱ្យបានឆាប់។ កុំប៉ះពាល់បក្សីដែលឆ្លងជំងឺ ដោយមិនបានពាក់ស្រោមដៃ ឬ ម៉ាស។ សូមមើល "ចំនុចត្រួតពិនិត្យទី ៥" លើទំព័រទី ៣១។

៤. សំអាត និង សម្លាប់មេរោគក្នុងទ្រុងបក្សី និង ឧបករណ៍ប្រើប្រាស់ជាមួយបក្សីឱ្យបានទៀងទាត់។

### របៀបបង្កើនការសហការ

១. ឧស្សាហ៍ទៅមណ្ឌលសង្គម (ដូចជា វត្ត ហាងលក់កាហ្វេ) ដើម្បីដឹង ព័ត៌មានដែលមានបច្ចុប្បន្នភាព។ រៀនឧទាហរណ៍ល្អៗ ដូចជា ទុកបក្សីក្នុងកន្លែង ដែលមានរបងបិទជិត ដោយប្រើប្រាស់វិធានការជីវសុវត្ថិភាពងាយៗ សំអាតនិងសម្លាប់មេរោគក្នុងទ្រុង និងឧបករណ៍នានាឱ្យបានទៀងទាត់ និង អនុវត្តទម្លាប់អនាម័យផ្ទាល់ខ្លួន។

២. ចែករំលែកការអនុវត្តល្អៗរបស់អ្នក ជាមួយកសិករ និង អ្នកធ្វើការងារជាមួយបក្សីដទៃទៀត។ ជួយកសិករជិតខាង ដែលមានភាពយឺតយ៉ាវក្នុងការកែលំអ។ សំខាន់ត្រូវបង្កើនកម្រិតការពារនៅក្នុងភូមិ និង សហគមន៍តែមួយ ដើម្បីធានាឱ្យមានការការពារជំងឺផ្តាសាយបក្សី។

### គន្លឹះណែនាំបន្ថែម

១. ធ្វើយ៉ាងណាកុំឱ្យក្មេងប៉ះពាល់បក្សីឈឺ និង ងាប់ និង រើសរោមបក្សី។ ក្មេងចូលចិត្តលេងជាមួយមាន់ និង ទា ហើយ តែងមានហានិភ័យឆ្លងជំងឺខ្ពស់។

២. អប់រំក្មេង និង សមាជិកគ្រួសារ អំពីវិធីអនាម័យផ្ទាល់ខ្លួន ដូចជា លាងដៃ និង ប្រើប្រាស់ឧបករណ៍ការពារ ។

៣. ទិញបក្សីតែពីប្រភព ដែលស្គាល់ និង មានការអនុញ្ញាតត្រឹមត្រូវ ។ កុំទិញបក្សីពីប្រភព ដែលមិនស្គាល់ ។

៤. ត្រូវរក្សាទុកឧបករណ៍ការពារខ្លួនឱ្យមានអនាម័យល្អ ។ ត្រូវបោះចោលម៉ាស និង ស្រោមដៃ ដែលពាក់ហើយបោះចោល ។ កុំយកវាទៅប្រើឡើងវិញឱ្យសោះ ។

៥. នៅពេលដែលអ្នកឃើញមានបក្សីឈឺ ឬ ងាប់ច្រើន កុំប៉ះពាល់វា ។ សូមទំនាក់ទំនងទៅកាន់ការិយាល័យកសិកម្ម ការិយាល័យបសុពេទ្យ ឬ ការិយាល័យសុខាភិបាលភ្នាម ។

៦. ការពារការឆ្លងរាលដាលជំងឺនេះ ដោយអនុវត្តសីលធម៌ពេលក្អក និង កណ្តាស គឺត្រូវគ្របមុខ និង ច្រមុះគ្រប់ពេល ។ ហើយ ត្រូវចោលក្រដាសអនាម័យ ឱ្យបានត្រឹមត្រូវ ។

៧. ការពារការឆ្លងរាលដាលជំងឺនេះ បន្ទាប់ពីមកពីកសិដ្ឋានដែលមានឆ្លងជំងឺវិញ ដោយលាងសំអាតខ្លួន កក់សក់ និង ដូរសម្លៀកបំពាក់ស្អាត មុនពេលចូលមកកាន់កសិដ្ឋានរបស់អ្នក ។

**ចំនុចដែលត្រូវចងចាំ**

កសិករ/អ្នកធ្វើការងារជាមួយបក្សី អាចលើកកម្ពស់ការចាប់ ឬកាន់បក្សីប្រកបដោយសុវត្ថិភាព ដោយប្រើវិធានការ ងាយៗ និងចំណាយប្រាក់តិច ។




រូបភាព ២.១ លាងដៃរបស់អ្នកជាមួយសាប៊ូ ក្រោយប៉ះពាល់បក្សីរួច ។ សំអាតបាតដៃ ម្រាមដៃ កដៃ និង ខ្នងដៃឱ្យបានស្អាតល្អ ។




រូបភាព ២.២ ប្រើប្រាស់វិធានការជីវសុវត្ថិភាព ដើម្បីកាត់បន្ថយហានិភ័យឆ្លងជំងឺផ្តាសាយបក្សី

## ចំនុចត្រួតពិនិត្យទី ៣

### *ប្រើប្រាស់របៀបសម្លាប់បក្សី ដោយសុវត្ថិភាព*

### អត្ថប្រយោជន៍សម្រាប់កសិករ/អ្នកធ្វើការងារជាមួយបក្សី

វិធីសម្លាប់បក្សី ដោយសុវត្ថិភាព គឺជាកត្តាសំខាន់ ក្នុងការការពារ កសិករ/អ្នកធ្វើការងារជាមួយបក្សី និង ក្រុមគ្រួសារពួកគេ មិនឱ្យឆ្លងជំងឺផ្តាសាយបក្សី។ នៅពេលសម្លាប់បក្សី កសិករ/អ្នកធ្វើការងារជាមួយបក្សីតែងតែប៉ះពាល់បក្សីយ៉ាងជិតស្និទ ដូច្នេះ ពួកគេត្រូវតែកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺនេះ ឱ្យនៅតិចជាអប្បបរមា។

អ្នកអាចកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺ ដោយប្រើប្រាស់វិធីងាយៗ អស់ចំណាយតិច ដូចជា ចាប់បក្សីដោយសុវត្ថិភាព ប្រើប្រាស់ឧបករណ៍ការពារ សំអាតទីសត្តឃាតឱ្យមានអនាម័យល្អ និង គ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវ។ កសិករ/អ្នកធ្វើការងារជាមួយបក្សី គួរសហការជាមួយអ្នកជិតខាងរបស់ខ្លួន ដើម្បីជម្រុញឱ្យមានការអនុវត្តតាមវិធានការងាយៗទាំងនេះ។

### របៀបកែលំអ

១. រកកន្លែងមុកសម្រាប់សម្លាប់ និង កាប់សាច់បក្សី និង ធ្វើរបងហ៊ុមជុំវិញកន្លែងនេះ ដើម្បីកុំឱ្យសត្វដទៃទៀត បក្សីព្រៃ និង សត្វល្អិតអាចចូលបាន។ កុំប្រើកន្លែងនេះ សម្រាប់គោលបំណងផ្សេងទៀត។

២. សង្កេតមើលមាន់ និង ទា ឱ្យបានប្រុងប្រយ័ត្ន មុនពេលចាប់វា។ កុំប៉ះពាល់វា ប្រសិនបើវាមើលទៅដូចជាឈឺ និង មានរោគសញ្ញាជំងឺផ្តាសាយបក្សី (សូមមើលរូបភាព ៥.១ ក្នុងចំនុចត្រួតពិនិត្យទី ៥)។ កុំសម្លាប់ បរិភោគ ឬ លក់បក្សីឈឺ។ ត្រូវចោលបក្សីនោះភ្លាម ប្រកបដោយអនាម័យត្រឹមត្រូវ។

៣. ប្រើប្រាស់ឧបករណ៍ការពារខ្លួន ដូចជា ម៉ាស ស្រោមដៃប្លាស្ទិក ស្បែកជើងកវែង និង អាវអៀម ដើម្បីការពារការប៉ះពាល់បក្សីដោយផ្ទាល់ (រូបភាព ៣.១)។ ពាក់ម៉ាសឱ្យបានត្រឹមត្រូវ (រូបភាព ៣.២)។ ឧបករណ៍ទាំងនេះ នឹងកាត់បន្ថយការប៉ះពាល់របស់អ្នក ជាមួយឈាម សារធាតុរាវក្នុងខ្លួនរបស់បក្សី និង ផ្នែកផ្សេងទៀតរបស់បក្សី។

៤. លាងដៃជាមួយសាប៊ូឱ្យបានស្អាតល្អ។ ត្រូវសំអាតបាតដៃ ម្រាមដៃ និង ខ្នងដៃឱ្យបានស្អាតល្អ។

៥. នៅក្នុងពេលសម្លាប់ ត្រូវការពារបក្សីដែលសម្លាប់រួចហើយ កុំឱ្យប៉ះនឹងកាកសំណល់របស់បក្សី ជាពិសេស អាចមិចេញពីពោះវៀន។

៦. សំអាត និង សម្លាប់មេរោគកន្លែង និង ឧបករណ៍សម្លាប់បក្សីឱ្យបានទៀងទាត់។

៧. ប្រើប្រាស់សំភារៈមិនជ្រាបទឹក សម្រាប់ធ្វើជាកម្រាល ដើម្បីងាយស្រួលលាងសំអាត និង សម្លាប់មេរោគ។

### របៀបចម្លើនការសហការ

ទៅជួបអ្នកជិតខាងរបស់អ្នក ដែលមានឧទាហរណ៍ល្អៗ និង សង្កេតមើលរបៀបដែលពួកគេសម្លាប់បក្សី និង រៀបចំសាច់ បក្សីរបស់ពួកគេ។ រៀនពីរបៀប ដែលពួកគេអាចបង្ការខ្លួនមិនឱ្យឆ្លងជំងឺផ្តាសាយបក្សី។ សុំដំបូន្មាន និង ការណែនាំខ្លះៗពីការិយាល័យកសិកម្ម និង ការិយាល័យបសុពេទ្យ អំពីរបៀបសម្លាប់បក្សី ដោយសុវត្ថិភាព។ ពិភាក្សាជាមួយអ្នកជិតខាងរបស់អ្នក អំពីវិធានការដើម្បីកាត់បន្ថយការប៉ះពាល់បក្សីដោយផ្ទាល់ និង កាត់បន្ថយហានិភ័យនៃការឆ្លងជំងឺ។ រៀនពីការអនុវត្តល្អៗរបស់អ្នកជិតខាង

របស់អ្នក ដូចជា ការប្រើប្រាស់ឧបករណ៍ការពារខ្លួន ការទុកកន្លែងសម្រាប់បក្សី ឬ វិធីលាងដៃប្រកបដោយប្រសិទ្ធភាព ។

## តម្រុយណែនាំបន្ថែម

១. ត្រូវមានជំនាញចាប់ និង សម្លាប់មាន់ និង ទា ដើម្បីកាត់បន្ថយការសាយភាយរោម ឈាម ទឹកបក្សី ។ល ។

២. កុំឱ្យក្មេង ឬ អ្នកដែលគ្មានបទពិសោធន៍ ចាប់មាន់ និង ទា ។

៣. កន្លែងសម្លាប់គួរមានខ្យល់ចេញចូល និង ភ្លើងបំភ្លឺឱ្យបានល្អ ។ បើកបង្អួច ។ ជ្រើសរើសកន្លែងភ្លឺ ។

៤. គួរប្រើប្រាស់ម៉ាស ដែលប្រើហើយចោល ហើយ ត្រូវចោលម៉ាសទាំងនេះ ក្រោយពេលប្រើប្រាស់រួច ។ សម្រាប់ម៉ាស ដែលប្រើហើយទុក ត្រូវលាងសំអាត និង សម្លាប់មេរោគ ក្រោយប្រើប្រាស់ហើយ ។

៥. លាងសំអាត និង សម្លាប់មេរោគស្រោមដៃប្លាស្ទិក ស្បែកជើងកវែង និង អាវអៀមភ្លាម ក្រោយប្រើប្រាស់រួច ជារៀងរាល់ថ្ងៃ ។ កុំបោកវា ជាមួយសម្លៀកបំពាក់ផ្សេងទៀត ។

៦. រៀបចំធុងពិសេស ទុកប្រមូលកាកសំណល់បក្សី និង ចោលកាកសំណល់ទាំងនេះ ប្រកបដោយអនាម័យត្រឹមត្រូវ (មើលចំនុចត្រួតពិនិត្យទី ៤) ។

សំអាត និង សម្លាប់មេរោគក្នុងកន្លែង និង លើឧបករណ៍ប្រើសម្រាប់សម្លាប់បក្សីឱ្យបានទៀងទាត់ ។ ត្រូវទុកឧបករណ៍ទាំងនេះឱ្យនៅឆ្ងាយពីកណ្តុរ និង កន្លាត ។

**ចំនុចដែលត្រូវចងចាំ**

កាត់បន្ថយការប៉ះពាល់បក្សីដោយផ្ទាល់ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។



រូបភាព ៣.១ ពាក់ម៉ាស ស្រោមដៃ ស្បែកជើងកវែង និង អាវអៀម នៅពេលអ្នកសម្លាប់បក្សី និង កាប់សាច់បក្សី ។ ប្រើតែកន្លែងបម្រុងទុក សម្រាប់សម្លាប់ និង កាប់សាច់បក្សី ។ កុំប្រើកន្លែងនេះ សម្រាប់គោលបំណងផ្សេងទៀត ។





*ម៉ាស់ស្តង់ដាសម្រាប់ពាក់ពេលវះកាត់* *ម៉ាសដង្ហើម N៩៥*

រូបភាព ៣.២ ពាក់ម៉ាស់ឱ្យបានប្រុងប្រយ័ត្ន។ កុំប៉ះផ្នែកខាងក្នុងរបស់ម៉ាស។ ម៉ាសនេះគួរត្រូវនឹងមុខរបស់អ្នក ហើយ មិនត្រូវឱ្យមានខ្យល់នៅចន្លោះមុខរបស់អ្នក និង ម៉ាសឡើយ។ ចំពោះការងារសម្លាប់បក្សីជាប្រចាំ អាចយកម៉ាសពាក់សម្រាប់វះកាត់ (ខាងឆ្វេង) ឬ ម៉ាសក្រណាត់មកពាក់បាន។ ប្រសិនបើអ្នកត្រូវប៉ះពាល់បក្សីឈឺ ឬ បក្សីដែលអាចឆ្លងជំងឺ អ្នកត្រូវពាក់ម៉ាសដង្ហើម *N៩៥* (ខាងស្តាំ)។

## ចំនុចត្រួតពិនិត្យទី ៤

## *អនុវត្តវិធីចោលបក្សី និង គ្រប់គ្រងកាកសំណល់ ប្រកបដោយអនាម័យល្អ*

### អត្ថប្រយោជន៍សម្រាប់កសិករ/អ្នកធ្វើការជាមួយបក្សី

កាកសំណល់របស់បក្សីឆ្លងជំងឺ ដូចជា រោមដែលនៅសល់ផ្នែករបស់ខ្លួនបក្សី សារធាតុរាវក្នុងខ្លួនរបស់បក្សី លាមក និង ជីដែលមានជាប់មេរោគមានវីរុសផ្តាសាយបក្សី ហើយ អាចជាប្រភពចម្លងជំងឺមួយ។ កសិករ គ្រួសារ និង អតិថិជនរបស់ពួកគេ ត្រូវតែចៀសវាងប៉ះពាល់កាកសំណល់របស់បក្សីដោយផ្ទាល់។ ត្រូវសំអាត និង សម្លាប់មេរោគក្នុងទ្រុងបក្សី និង របស់ របរនានា ដូចជា ធុងដាក់ទឹក និង ចំណី ឱ្យបានទៀងទាត់។

វិធីចោលបក្សីប្រកបដោយអនាម័យត្រឹមត្រូវ និង ការគ្រប់គ្រងកាកសំណល់បានត្រឹមត្រូវអាចកាត់បន្ថយហានិភ័យនៃការចម្លងជំងឺផ្តាសាយបក្សី មកកាន់កសិករ គ្រួសារ និង អតិថិជនរបស់ពួកគេ។ មានវិធីងាយៗ អស់ចំណាយតិចជាច្រើន ដើម្បីចោលបក្សីប្រកបដោយអនាម័យត្រឹមត្រូវ និង កែលំអការគ្រប់គ្រងកាកសំណល់ប្រកបដោយអនាម័យ។

### របៀបកែលំអ

១. ពាក់ម៉ាសឱ្យបានត្រឹមត្រូវ (រូបភាព ៣.២) គ្រប់ពេលដែលអ្នកប្រមូលកាកសំណល់បក្សី។ ប្រើស្រោមដៃប្លាស្ទិក និង ស្បែកជើងកវែង ដើម្បីការពារខ្លួនអ្នក។

២. រៀបចំធុងពិសេស ដើម្បីប្រមូលកាកសំណល់របស់បក្សី។ ដាក់ថង់ប្លាស្ទិកធំនៅខាងក្នុង ដើម្បីងាយស្រួលចោលកាកសំណល់ដែលប្រមូលបាន។

៣. គួរដុត និង កប់កាកសំណល់ដែលប្រមូលបាន។ ប្រសិនបើកប់ អ្នក ត្រូវបម្រុងទុកកន្លែងមួយសម្រាប់កប់ ដោយជីករណ្តៅជម្រៅជាង ៥០ សង់ទីម៉ែត្រ ហើយ កប់ថង់ ដែលមានកាកសំណល់។ បាញ់ថ្នាំ សម្លាប់មេរោគលើកាកសំណល់ មុនពេលកប់ និង បាញ់ម្តងទៀត លើរណ្តៅ ក្រោយកប់ហើយ។ ត្រូវធ្វើរបងព័ទ្ធជុំវិញកន្លែងកប់នេះ ដើម្បីកុំឱ្យមានសត្វផ្សេងមកកកាយ។ ប្រាប់គ្រួសារ និង កសិករ ដទៃទៀតកុំឱ្យមកជិតកន្លែងនេះ។

៤. បន្ទាប់ពីលក់បក្សីអស់ ហើយ មុនពេលយកបក្សីថ្មីចូលមក ត្រូវសំអាត និង សម្លាប់មេរោគក្នុងទ្រុងបក្សី (រូបភាព ៤.១)។ ពាក់មួក ម៉ាស ស្រោមដៃ និង ស្បែកជើងកវែង ដើម្បីការពារខ្លួន។

៥. ត្រូវរកកន្លែងកប់ ឱ្យនៅឆ្ងាយពីប្រភពទឹកសាធារណៈ។

៦. អ្នកដែលប៉ះពាល់បក្សី ត្រូវអនុវត្តទម្លាប់អនាម័យផ្ទាល់ខ្លួនឱ្យបានល្អ និង គួរពាក់ឧបករណ៍ការពារខ្លួន។

៧. ទូរស័ព្ទទៅកាន់មន្ត្រីបសុពេទ្យ ឬ មន្ត្រីសុខាភិបាល ដែលនៅជិតបំផុតភ្លាម នៅពេលដែលអ្នកឃើញមានបក្សីងាប់ និង ឈឺ ហើយសង្ស័យថាវាឆ្លងជំងឺផ្តាសាយបក្សី។
ស្តាប់មន្ត្រីទាំងនោះដោយប្រុងប្រយ័ត្ន និង ធ្វើតាមការណែនាំរបស់ពួកគេ។ បញ្ឈប់មនុស្ស និង សត្វ មិនឱ្យចូល និង ចេញពីកសិដ្ឋាន។ អ្នកចោលបក្សីដែលងាប់ ត្រូវពាក់សម្លៀកបំពាក់ការពារខ្លួនឱ្យបានត្រឹមត្រូវ (រូបភាព ៤.២)។ កុំទុកបក្សីងាប់ ឱ្យនៅពេញក្នុងកសិដ្ឋាន។

### របៀបបង្កើនការសហការ

សម្លឹងមើលកន្លែងធ្វើការរបស់អ្នក និង ពិនិត្យឡើងវិញលើរបៀបរបងធ្វើការងាររបស់អ្នក។ រកកន្លែងដែលអាចប៉ះពាល់ជាមួយកាកសំណល់របស់បក្សី។ ពិភាក្សាជាមួយគ្រួសារ និង កសិករជិតខាងរបស់អ្នក អំពីរបៀបចៀសវាងការប៉ះពាល់ជាមួយកាកសំណល់បក្សី ដោយផ្ទាល់។ រៀនពីការអនុវត្តល្អៗ ដែលកសិករផ្សេងទៀតបានធ្វើរួចទៅហើយ។

## គន្លឹះណែនាំបន្ថែម

១. កុំដាក់កាកសំណល់បក្សីលាយឡំ ជាមួយកាកសំណល់ទូទៅរបស់ គ្រួសារ និង របស់កសិដ្ឋាន។

២. ដាក់ធុងពិសេសមួយ ដើម្បីប្រមូលកាកសំណល់ ក្នុងកន្លែងដែលអ្នកសម្លាប់បក្សី។ សំអាត និង សម្លាប់មេរោគលើកម្រាលធុង ឧបករណ៍ និង តុប្រើប្រាស់ ឱ្យបានទៀងទាត់។

៣. រៀបចំសាច់បក្សីឱ្យបានប្រុងប្រយ័ត្ន ទៅតាមរបៀបរបបសម្លាប់បក្សី និង ធ្វើយ៉ាងណាកុំឱ្យសាច់បក្សីប៉ះពាល់ជាមួយកាកសំណល់ របស់បក្សី។

៤. ប្រសិនបើអ្នកមានមាន់ ឬ ទាច្រើន ហើយមានកាកសំណល់ច្រើន អ្នកត្រូវទិញចង្ក្រានដុតសម្រាម ដែលអាចដុតសម្រាមក្នុងចំនួនច្រើនបាន។

៥. អ្នកដែលប៉ះពាល់បក្សី ត្រូវអនុវត្តអនាម័យផ្ទាល់ខ្លួនឱ្យបានល្អ និង ផ្លាស់សម្លៀកបំពាក់ចេញមុន និង ក្រោយពេលប៉ះពាល់បក្សី។

៦. គួរបោកសំអាត និង សម្លាប់មេរោគលើឧបករណ៍ការពារ ដែលអាចយកមកពាក់សារជាថ្មី (ដូចជា អាវ អៀម ស្បែកជើងកវែង សម្លៀកបំពាក់ ស្រោមដៃ) ជាប្រចាំថ្ងៃ។

**ចំនុចដែលត្រូវចងចាំ**

ប្រមូល និង ចោលកាកសំណល់បក្សីឱ្យបានត្រឹមត្រូវ។ ពិគ្រោះយោបល់ជាមួយមន្ត្រីកសិកម្ម ឬ មន្ត្រីបសុពេទ្យ នៅក្នុងតំបន់របស់អ្នក អំពីរបៀបប្រមូល និង ចោលកាកសំណល់បក្សី។



រូបភាព ៤.១ សំអាត និង សម្លាប់មេរោគក្នុងកសិដ្ឋានបក្សីរបស់អ្នក និង យកសម្រាមចេញ ក្រោយពេលដែលអ្នកលក់បក្សីអស់ និង យកបក្សីថ្មីចូល។ នេះនឹងការពារបក្សីថ្មីរបស់អ្នក មិនឱ្យឆ្លងជំងឺផ្តាសាយបក្សី។



រូបភាព ៤.២ ធ្វើតាមការណែនាំរបស់មន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ និង មន្ត្រីសុខាភិបាល នៅពេលចោលបក្សី ដែលសង្ស័យថាឆ្លងជំងឺផ្តាសាយបក្សី ។ ប្រើថង់ និង ធុងពិសេស ដើម្បីប្រមូលបក្សីងាប់ និង ដុត ឬ កប់វាចោល ។ អ្នកកប់បក្សីត្រូវពាក់ម៉ាសដង្ហើម N៩៥ វ៉ែនតាការពារ ស្រោមដៃ ស្បែកជើងកវែង និង សម្លៀកបំពាក់ការពារ ដើម្បីការពារការឆ្លងជំងឺ ។ បញ្ឈប់មនុស្ស និង សត្វ មិនឱ្យចូល និង ចេញ ដោយធ្វើរបងព័ទ្ធជុំវិញកន្លែងនេះ ឱ្យបានត្រឹមត្រូវ ។

# ទំនុកទ្រូងចំនិតទី ៥

## *រាយការណ៍ពីជំងឺជាបន្ទាន់*

### អត្ថប្រយោជន៍សម្រាប់កសិករ/អ្នកធ្វើការជាមួយបក្សី

ការរាយការណ៍ជាបន្ទាន់របស់អ្នក អំពីករណីបក្សីឈឺ និង ងាប់ អាចជួយឱ្យមានការឆ្លើយតបជាបន្ទាន់ ពីមន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬ មន្ត្រីសុខាភិបាល និង បង្ការការឆ្លងរាលដាលជំងឺផ្តាសាយបក្សី។ ការរាយការណ៍របស់អ្នក អាចបង្ការមិនឱ្យបក្សីដទៃទៀតនៅក្នុងភូមិរបស់អ្នក និង ភូមិដទៃទៀត ឆ្លងជំងឺ។ ការអនុវត្តវិធានការបង្ការជាបន្ទាន់ អាចបង្កើនការការពារគ្រួសាររបស់អ្នក និង អ្នកភូមិដទៃទៀត។

ជាការសំខាន់ដែលអ្នកត្រូវដឹងពីរោគសញ្ញាបក្សី ដែលឆ្លងជំងឺផ្តាសាយបក្សី។ រោគសញ្ញា ដែលឧស្សាហ៍កើតមាន រួមមានៈ ចុះខ្សោយ រញីរញ៉ូវ ភ្នែកក្រហម ហៀរសំបោរនិងចេញទឹកតាមមាត់ មានស្នាមជាំឈាមក្នុងភ្នែក មាត់ ឬ លើជើង ។ល។ (រូបភាព ៥.១)។ ប្រសិនបើអ្នក និង គ្រួសាររបស់អ្នកសង្កេតឃើញមានរោគសញ្ញាទាំងនេះលើបក្សីរបស់អ្នក ត្រូវជូនដំណឹងដល់មេភូមិ ឬ អ្នកស្ម័គ្រចិត្តសហគមន៍ភ្លាម។

### របៀបកែលំអ

១. ដឹងពីរោគសញ្ញារបស់បក្សី ដែលឆ្លងជំងឺផ្តាសាយបក្សី។

២. សង្កេតមើលបក្សីរបស់អ្នក ដោយប្រុងប្រយ័ត្ន ជារៀងរាល់ថ្ងៃ។ កុំមើលរំលងរោគសញ្ញា ដែលទើបលេចចេញមក។ ប្រសិនបើបក្សីចុះខ្សោយ ហើយ មិនសូវសកម្ម ឬ ដូរពណ៌ភ្នែក ត្រូវជូនដំណឹងដល់មន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬ មន្ត្រីសុខាភិបាលភ្លាម។

៣. រាយការណ៍ពីករណីបក្សីឈឺ និង ងាប់ដែលសង្ស័យភ្លាម ដល់អ្នកដឹកនាំសហគមន៍ អ្នកស្ម័គ្រចិត្ត មន្ត្រីកសិកម្ម/បសុពេទ្យ និង/ឬ អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធផ្សេងទៀត។ ទោះបីជាអ្នកមិនប្រាកដថាវាជាជំងឺផ្តាសាយបក្សីក៏ដោយ ក៏អ្នកត្រូវតែពិគ្រោះយោបល់ជាមួយពួកគេដែរ។

៤. នៅពេលដែលអ្នក ឬ សមាជិកគ្រួសាររបស់អ្នកក្តៅខ្លួនខ្លាំង និង មានរោគសញ្ញាផ្តាសាយធ្ងន់ធ្ងរ ដូចជា ក្អក កណ្តាស ឬ ចុះខ្សោយ សូមទំនាក់ទំនងវេជ្ជបណ្ឌិត ឬ អង្គភាពថែទាំសុខភាពបឋម (PCU) នៅក្នុងភូមិរបស់អ្នកភ្លាម។

៥. ប្រសិនបើអ្នកជំងឺធ្លាប់ប៉ះពាល់បក្សីស្រុក បក្សីព្រៃ ឬ កាកសំណល់របស់វា អ្នកត្រូវជូនដំណឹងដល់វេជ្ជបណ្ឌិត បុគ្គលិក PCU និង អ្នកស្ម័គ្រចិត្តសុខាភិបាលភ្លាម។ ព័ត៌មាននេះមានប្រយោជន៍ណាស់សម្រាប់ធ្វើរោគវិនិច្ឆ័យជំងឺឱ្យបានត្រឹមត្រូវ និង ផ្តល់លទ្ធភាពឱ្យអ្នកជំងឺទទួលបានការព្យាបាលត្រឹមត្រូវភ្លាមៗ។

### របៀបបង្កើនការសហការ

សិក្សាពីរោគសញ្ញារបស់ជំងឺផ្តាសាយបក្សី ជាមួយកសិករ និង អ្នកភូមិដទៃទៀត។ មន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ និង មន្ត្រីសុខាភិបាលក្នុងមូលដ្ឋានអាចជួយអ្នកបាន។ រៀនសូត្រពីករណីមុនៗ អំពីរបៀបដែលបក្សី និង មនុស្សឆ្លងជំងឺផ្តាសាយបក្សី និង របៀបដែលមនុស្សនៅក្នុងតំបន់មានជំងឺនាំគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺនេះ។ ពិភាក្សាពីវិធីជម្រុញឱ្យមានការរាយការណ៍ពីជំងឺនេះភ្លាមៗ និង របៀបបង្កើនការសហការគ្នារវាងកសិករ និង កសិករ។

### គន្លឹះណែនាំបន្ថែម

១. អ្នកត្រូវស្គាល់អ្នកស្ម័គ្រចិត្តសុខាភិបាល ឬ អ្នកស្ម័គ្រចិត្តខាងការចិញ្ចឹមសត្វ នៅក្នុងភូមិរបស់អ្នក។ ពួកគេនឹងជួយអ្នក ក្នុងការរាយការណ៍ឱ្យបានត្រឹមត្រូវ។

២. ជំងឺផ្តាសាយបក្សីអាចចម្លងមិនត្រឹមតែមកកសិករប៉ុណ្ណោះទេ ថែមទាំងមកកាន់អ្នកលក់ស៊ុត និង សាច់បក្សី ដែលមានជាប់កាកសំណល់បក្សីឈឺថែមទៀតផង។ ជួយអ្នកលក់ទាំងនេះឱ្យដឹងពីព័ត៌មានអំពីជំងឺ។

៣. នៅពេលដែលអ្នកនឹងបាត់បង់បក្សីរបស់អ្នក ដោយសារជំងឺផ្តាសាយបក្សី អ្នកអាចទទួលបានសំណងខូចខាត ឬ ការគាំទ្រពីរដ្ឋាភិបាល ។ អ្នកត្រូវទំនាក់ទំនងទៅកាន់ការិយាល័យរបស់រដ្ឋាភិបាល ។ អ្នកអាចជូនដំណឹងដល់កសិករជាមិត្តភ័ក្ត្ររបស់អ្នកដែលបានបាត់បង់បក្សីរបស់ពួកគេរួចទៅហើយ ។

៤. កុំសម្លាប់ និង លក់សាច់បក្សីឈឺ និង ងាប់ ។

**ចំនុចដែលត្រូវចងចាំ**

ការរាយការណ៍ភ្លាមៗ និង ការឆ្លើយតបឆាប់រហ័សអាចបង្ការ ការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និង កាត់បន្ថយគ្រោះថ្នាក់ឱ្យនៅជាអប្បបរមា ។




**រូបភាព ៥.១ កុំទៅជិតមាន់ឈឺ ឬ ងាប់ ។ នាំក្មេងឱ្យចៀសឆ្ងាយពីវា ។**



រូបភាព ៥.២ រាយការណ៍ជាបន្ទាន់ទៅកាន់មន្ត្រីកសិកម្ម មន្ត្រីបសុពេទ្យ ឬ មន្ត្រីសុខាភិបាល និង/ឬ អាជ្ញាធររដ្ឋាភិបាល ដែលពាក់ព័ន្ធដទៃទៀត នៅពេលដែលអ្នកឃើញមាន់ ទា ឬ បក្សីដទៃទៀតងាប់សង្ស័យថាឆ្លងជំងឺ រួមទាំង បក្សីព្រៃផងដែរ។



រូបភាព ៥.៣ រៀនពីរោគសញ្ញាជំងឺផ្តាសាយបក្សី លើមនុស្សឱ្យបានឆាប់

# ឧបសម្ព័ន្ធទី ១

## ប្រភពព័ត៌មាន

មជ្ឈមណ្ឌលត្រួតពិនិត្យជំងឺផ្ដាសាយបក្សី
ការិយាល័យត្រួតពិនិត្យជំងឺ និង សេវាបសុពេទ្យ
នាយកដ្ឋានអភិវឌ្ឍន៍សត្វពាហនៈ
ក្រសួងកសិកម្ម និង សហប្រតិបត្តិការ
69/1 ផ្លូវ Phayathai, Rachathevi
បាងកក 10400
ទូរស័ព្ទ : 02 653 4444
ទូរសារ : 02 653 4862 / 653 4929
អ៊ីមែល : dcontrol@dld.go.th
វ៉ិបសាយ : http://www.dld.go.th/dcontrol/

ការិយាល័យជំងឺឆ្លងថ្មី១
នាយកដ្ឋានត្រួតពិនិត្យជំងឺ
ក្រសួងសុខាភិបាលសាធារណៈ
ជាន់ទី 4 អាគារទី 8 ផ្លូវ Tiwanond
ខេត្តណុនថៈបុរី
ទូរស័ព្ទ : 02 590 3157-9
វ៉ិបសាយ : http://beid.ddc.moph.go.th/th/index.php

អង្គការស្បៀង និង កសិកម្មនៃសហប្រជាជាតិ (FAO)
ការិយាល័យប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក (RAP)
ភូមិគ្រឹះ Maliwan ផ្លូវ Phra Attit
បាងកក 10400
ទូរស័ព្ទ : 02 697 4000
ទូរសារ : 02 697 4445
វ៉ិបសាយ : http://www.fao.org/world/regional/rap

ក្រសួងការងារ
ផ្លូវ Mitmaitree, Dindaeng
បាងកក 10200
ទូរស័ព្ទ : 02 232 1421-2
វ៉ិបសាយ : http://www.mol.go.th

ការិយាល័យតំណាងអង្គការសុខភាពពិភពលោក (WHO)
ប្រចាំប្រទេសថៃ
c/o ក្រសួងសុខាភិបាលសាធារណៈ
ផ្លូវ Tiwanond, Muang
ណុនថៈបុរី 11000
ទូរស័ព្ទ : 02 590 1524
វ៉ិបសាយ : http://w3.whothai.org/en/index.htm

ការិយាល័យសម្របសម្រួលជំងឺផ្ដាសាយរបស់ប្រព័ន្ធសហប្រជាជាតិ (UNSIC)
បណ្ដាញតំបន់អាស៊ីប៉ាស៊ីហ្វិក
ការិយាល័យរបស់ UN OCHA ប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក
ជាន់ទី 2 អាគារ UNCC
វិថី Rajdamnern Nok
ទូរស័ព្ទ : 02 288 1234
វ៉ិបសាយ : http://www.influenza.undg.org
http://un-influenza.org

អង្គការសុខភាពសត្វពិភពលោក

ការិយាល័យសម្របសម្រួល OIE ប្រចាំអនុតំបន់អាស៊ីអាគ្នេយ៍

c/o នាយកដ្ឋានអភិវឌ្ឍន៍សត្វពាហនៈ

ក្រសួងកសិកម្ម និង សហប្រតិបត្តិការ

69/1 ផ្លូវ Phayathai, Rachathevi

បាងកក 10400

ទូរស័ព្ទ : 02 653 4864

វ៉ិបសាយ : http://www.oie.int/eng/en_index.htm

# ការពារសុខភាព និង អាជីវកម្មរបស់អ្នកពីជំងឺផ្តាសាយបក្សី

## សៀវភៅណែនាំអំពីសកម្មភាពសំរាប់កសិករ និង អ្នកធ្វើការងារជាមួយបសុបក្សី

ការផ្ទុះជំងឺផ្តាសាយបក្សី និងការកើតឡើងជាបន្តបន្ទាប់នូវជំងឺឆ្លងនានា បានបង្កឱ្យមានការព្រួយបារម្ភ នៅទូទាំងសកលលោក។ សៀវភៅណែនាំអំពីការបណ្តុះបណ្តាលនេះ ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយសុវត្ថិភាព។ សៀវភៅណែនាំនេះ គឺងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងមានលក្ខណៈជាការអនុវត្តជាក់ស្តែង ដោយផ្តល់នូវបញ្ជីផ្ទៀងផ្ទាត់សកម្មភាពអំពីវិធានការបង្ការផ្សេងៗ រួមទាំងមានការពន្យល់ និងសេចក្តីអធិប្បាយ។ វិធីសាស្ត្របណ្តុះបណ្តាលមានលក្ខណៈជាការចូលរួមពិសេសដោយឡែករបស់អង្គការ ILO គឺកម្មវិធីកែលំអការងារ និងអភិវឌ្ឍន៍ភូមិដ្ឋាន (WIND) និងកម្មវិធីកែលំអការងារនៅតាមសហគ្រាសខ្នាតតូច (WISE) ត្រូវបានប្រើប្រាស់ដើម្បីបង្កើនការយល់ដឹង និងលើកទឹកចិត្តឱ្យមានការកែលំអសកម្មភាពរបស់កសិករ និងអ្នកធ្វើការងារជាមួយបសុបក្សី។

ព័ត៌មានទំនាក់ទំនង :

ការិយាល័យអនុតំបន់របស់អង្គការពលកម្មអន្តរជាតិ ប្រចាំអាស៊ីបូព៌ា

អាគារសហប្រជាជាតិ ជាន់ទី 10

វុក្ខវិថី Rajdamnern Nok

បាងកក 10200 ប្រទេសថៃ

ទូរស័ព្ទ : +662 288 1234

ទូរសារ : +662 288 3058

អ៊ីមែល : bangkok@ilo.org
www.ilo.org/asia

DECENT WORK
A better world starts here
90 years working for social justice

ISBN: 978-92-2-822345-3